ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Nov-2014, 15:02
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ (ជាមួយឧបសម្ព័ន្ធ សម្ងាត់)**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំបញ្ចូលឯកសារថ្មីរបស់លោក ខៀវ សំផន ក្នុងកិច្ចពិភាក្សាដេញដោល**

**(លិខិតរបស់ 2-TCE-81)**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះតុលាការ**សាលាដំបូង

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូ ឧត្តរា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

កញ្ញា អ៊ុំច ស្រីផាត

លោក BOSSIS Clément

**មេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីខាងការពារក្តីរបស់លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. តាមរយៈសំណើ ចុះថ្ងៃទី ៩ ឧសភា និង ១៩ ខែមិថុនា ឆ្នាំ២០១៤[1] ក្រុមមេធាវីការពារក្ដីរបស់ លោក ខៀវ សំផន បានស្នើសុំឲ្យកោះហៅអ្នកជំនាញថ្មី ដែលមានលេខកូដ 2-TCE-81 ទាក់ទងនឹងនយោបាយរៀបការដោយបង្ខំ ដែលនឹងត្រូវយកមកពិនិត្យ ក្នុងសំណុំរឿង ០០២/០២។ ក្រុមមេធាវីការពារក្ដី ក៏បានរំឭកផងដែរថា ស្នាដៃរបស់អ្នកជំនាញនោះ ក៏ត្រូវបានដាក់បញ្ចូល ដើម្បីប្រើប្រាស់ជាភស្តុតាង នៅក្នុងសំណុំរឿង ០០២/០១ ផងដែរ។[2]

២. តាមរយៈសេចក្ដីសម្រេច ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤[3] អង្គជំនុំជម្រះបានចាត់ទុកថា សំណើសុំទាំងនោះមិនអាចត្រូវបានចាត់ទុកថា ជាការស្នើសុំដាក់ភស្តុតាងថ្មី អនុលោមតាម វិធាន ៨៧.៤ បានឡើយ ដូច្នេះ គេគួរតែចាត់ទុកថា អ្នកជំនាញ 2-TCE-81 ស្ថិតនៅជាផ្លូវការ នៅក្នុងបញ្ជីសាក្សីនៃក្រុមមេធាវីការពារក្ដី សម្រាប់សំណុំរឿង ០០២/០២ ហើយស្នាដៃរបស់ អ្នកជំនាញរូបនេះ ក៏ស្ថិតក្នុងចំណោមភស្តុតាងដែលភាគីនឹងអាចយកមកប្រើបាន នៅក្នុងពេល ពិភាក្សាដេញដោលបានដែរ។

៣. នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុមមេធាវីការពារក្ដីរបស់ លោក ខៀវ សំផន បានទទួល ដំណឹងពីលិខិតដែលផ្ញើដោយអ្នកជំនាញ 2-TCE-81 ទៅកាន់សារព័ត៌មានមួយ នៅកាល បរិច្ឆេទដដែលនោះ។[4]

---

[1] សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្ដីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ **E305/5** ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ **E305/5.1** (បញ្ជីឈ្មោះ) និង **E305/5.2** (សេចក្ដីសង្ខេប) ។ សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យកោះហៅអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២ (វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង) ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ **E307/2** ។

[2] សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យកោះហៅអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២ (វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង) ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ **E307/2** កថាខណ្ឌ ៨ និងកំណត់ជើងទំព័រ ទី៩។

[3] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពី "សេចក្ដីសម្រេចលើសំណើសុំរួមឲ្យសម្រេចសាជាថ្មីឡើងវិញលើ ការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ **E307/1/2** ។

[4] លិខិតរបស់ 2-TCE-81 ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤ មានភ្ជាប់ជាមួយនូវអត្ថបទកាសែត នៅក្នុងឧបសម្ព័ន្ធ។

៤. នៅថ្ងៃនេះ ដោយអនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំឱ្យដាក់បញ្ចូលឯកសារនេះទៅក្នុងការពិភាក្សាដេញដោល និងទទួលយកជាភស្តុតាង។[5]

៥. វាជាការមិនអាចប្រកែកបានឡើយដែលថា លិខិតនេះមិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះក្តីឡើយ។ ទោះបីជាមានចេតនាខំប្រឹងប្រែងយ៉ាងណា ក៏ក្រុមមេធាវីការពារក្តីមិនអាចរកបានលិខិតនោះ មុនពេលដែលវាត្រូវបានចុះផ្សាយនៅក្នុងកាសែតឡើយ...។

៦. លើសពីនោះទៀត ឯកសារថ្មីនេះមានសារប្រយោជន៍សម្រាប់ការស្វែងរកការពិត និង បំពេញតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវាក្យខណ្ឌទី៣ នៃវិធាន ៨៧។[6]

៧. ពីព្រោះថា នៅក្នុងលិខិតនេះ អ្នកជំនាញ 2-TCE-81 រំឭកពីវិធីសាស្ត្រស្រាវជ្រាវរបស់ខ្លួន និងពន្យល់ពីចំណុចដែលនាំឱ្យខ្លួនធ្វើការសិក្សា និងចោទសួរឡើងវិញពីការប្រើពាក្យ "ការរៀបការដោយបង្ខំ" ដែលគេយកមកប្រើពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៨. យោបល់របស់អ្នកជំនាញ 2-TCE-81 ដូចមានបង្ហាញក្នុងអត្ថបទនោះ គឺពិតជាចំណុចដ៏សំខាន់ ដែលក្រុមមេធាវីការពារក្តីមានបំណងយកមកពិភាក្សានៅក្នុងក្របខណ្ឌនៃសំណុំរឿង

---

[5] « ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុ នៃការស្នើសុំនេះឱ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។».

[6] « (...) អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា។ ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ។ គ-មិនសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។ »

០០២/០២។ វាក៏ផ្តល់ផងដែរនូវធាតុផ្សំចាំបាច់ ដើម្បីយល់ច្បាស់ពីការស្រាវជ្រាវនៅថ្នាក់សាកលវិទ្យាល័យរបស់អ្នកជំនាញ 2-TCE-81 និងជួយដល់ភាគីនានាក្នុងការរៀបចំការសួរសំណួររបស់ខ្លួនទៅកាន់អ្នកជំនាញម្នាក់ នេះ។

៩. ម្យ៉ាងវិញទៀត ក្រុមមេធាវីការពារក្តីនឹងស្នើសុំឱ្យបកប្រែអត្ថបទខ្លីនេះ ដែលនឹងអាចប្រើប្រាស់បានជាបីភាសាការងាររបស់តុលាការ មុននឹងការចូលបង្ហាញខ្លួនរបស់អ្នកជំនាញ 2-TCE-81 និង/ឬអ្នកជំនាញដទៃទៀតពាក់ព័ន្ធនឹង "ការរៀបការដោយបង្ខំ" ដែលអង្គជំនុំជម្រះមានបំណងចង់ស្តាប់។

១០. អាស្រ័យ**ហេតុនេះ** ក្រុមមេធាវីការពារក្តីរបស់ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះមេត្តា **ដាក់បញ្ចូល** ឯកសារថ្មីនេះទៅក្នុងកិច្ចពិភាក្សាដេញដោល និង**ទទួលយក** ជាឯកសារភស្តុតាង។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |